ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម
# ចិញ្ចឹមទាតែវ៉ាន់






រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម**


ខែឧសភា ឆ្នាំ២០២៥


023 220 811
023 220 810
095 416 878
# 168, Street 7, Prek Leap Village, Sangkat Prek Leap, Khan Chroy Changva, Phnom Penh

# មាតិកា

**១- សេចក្តីផ្តើម** ........................................ ១
**២-បច្ចេកទេសចិញ្ចឹម** ........................................ ១
២-១- ការជ្រើសរើសកូនទាតៃវ៉ាន់ ........................................ ១
២-២- ការរៀបចំទីជម្រកទាតៃវ៉ាន់ ........................................ ២
២-៣- ការថែទាំកូនទាតៃវ៉ាន់ ........................................ ៣
២-៤- ទឹក និងចំណីទាតៃវ៉ាន់ ........................................ ៤
**៣-វិធី ការការពារ និងការថែរក្សាសុខភាពទាតៃវ៉ាន់** ........................................ ៤
៣-១- ជំងឺផ្តាសាយបក្សី ........................................ ៤
៣-២- ជំងឺប៉េស្តទាតៃវ៉ាន់ ........................................ ៥
**៤-តម្លៃ និងទីផ្សារ** ........................................ ៦
៤-១- តម្លៃ ........................................ ៦
៤-២- ទីផ្សារ ........................................ ៦
៤-៣- គម្រោងនៃការចំណាយលើការចិញ្ចឹមទាតៃវ៉ាន់សាច់ ២,០០០ក្បាល/វគ្គ ........................................ ៦
៤-៤- ការប្រមូលផលទាតៃវ៉ាន់ ........................................ ៧
**៥-ការវិភាគសេដ្ឋកិច្ច** ........................................ ៧
៥-១- ការវិភាគលើតម្លៃលក់ទាតៃវ៉ាន់សាច់អាយុ២ខែ ........................................ ៨
៥-២- ការវិភាគទៅលើអត្រាបាត់បង់ ........................................ ៩
**៦-ហានិភ័យ វិធានការ និងអនុសាសន៍** ........................................ ៩
**៧-សេចក្តីសន្និដ្ឋាន** ........................................ ១០

## ១- សេចក្តីផ្តើម

ការចិញ្ចឹមទាតៃវ៉ាន់សម្រាប់ផ្គត់ផ្គង់សាច់ទៅទីផ្សារជាជម្រើសដ៏ល្អបំផុត ដោយសារសត្វទាអាចធំធាត់លឿន និងសាច់មានគុណភាពខ្ពស់ ឆាប់ប្រមូលផលក្នុងរយៈពេលត្រឹមតែ ៤៥ ទៅ៥០ថ្ងៃ នៅក្នុងសាច់ទាមានសារធាតុខ្លាញ់តិច និងមានតម្រូវការទីផ្សារខ្ពស់។ ការចិញ្ចឹមសត្វទាតៃវ៉ាន់ កសិករងាយស្រួលផ្តល់ចំណីដោយសត្វទាចូលចិត្តរស់នៅក្បែរប្រភពទឹក និងស្វែងរកចំណីទាំងក្នុងទឹក និងលើគោក ហើយអាចធន់ទ្រាំនឹងអាកាសធាតុត្រជាក់បាន។ ដើម្បីចិញ្ចឹមទាតៃវ៉ាន់ទទួលបានជោគជ័យ និងទិន្នផលខ្ពស់ ទាមទារឱ្យកសិករចិញ្ចឹមត្រូវគិតគូរពីការជ្រើសរើសកូនទាពូជ របៀបថែទាំសុខភាព ជ្រើសរើសចំណីដែលមានសារធាតុចិញ្ចឹមគ្រប់គ្រាន់ និងរបៀបផ្តល់ចំណីទៅតាមដំណាក់កាលនៃការលូតលាស់របស់សត្វទា ការប្រើប្រាស់ថ្នាំ វ៉ាក់សាំង និងទីធ្លាចិញ្ចឹមមានលក្ខណៈសមស្រប និងការអនុវត្តតាមលំដាប់លំដោយបច្ចេកទេសចិញ្ចឹមដែលទទួលបានពីអ្នកបច្ចេកទេស ក្រុមហ៊ុនចំណី និងអ្នកផ្គត់ផ្គង់កូនទាដែលមានបទពិសោធន៍ជាយូរឆ្នាំ ។

## ២- បច្ចេកទេសចិញ្ចឹម

### ២-១-ការជ្រើសរើសកូនទាតៃវ៉ាន់

**ក)-<u>លក្ខណៈសម្គាល់ភិនភាគរបស់កូនទាតៃវ៉ាន់មាន</u>÷**

រោមពណ៌លឿងពេលនៅតូច និងប្តូរជាពណ៌សនៅពេលធំឡើង ចំពុះនិងជើងមានពណ៌ទឹកក្រូចមានទ្រូងទូលាយ ក្បាលធំ និងមូល ហើយមានអាកប្បកិរិយាស្ងប់ស្ងាត់។

**ខ)-<u>កត្តាសំខាន់ៗនៃការជ្រើសរើសកូនទាតៃវ៉ាន់</u> ÷**

-មានប្រភពច្បាស់លាស់ពីកន្លែងភ្ញាស់កូនទាត្រឹមត្រូវ

-ជ្រើសយកកូនទាដែលមានអត្រាឈ្មោលខ្ពស់ មានដងខ្លួនវែង និងអត្រាធំធាត់លឿន

-មានរោមល្អភ្លឺរលោង និងភ្នែកភ្លឺថ្លា ជើងមានទ្រង់ទ្រាយល្អ មិនមានស្នាមរបួស

-ពូកែស៊ីចំណី ផឹកទឹក មានសុខភាពល្អ និងមិនមានជំងឺ ឬមិនធ្លាប់កើតជំងឺឆ្លង

ប្រភេទទាតៃវ៉ាន់ជាពូជទាដែលល្អសម្រាប់ផលិតកម្មសាច់។ ទាតៃវ៉ាន់អាយុ៦ ទៅ៨សប្តាហ៍អាចមានទម្ងន់ចន្លោះពី ២,៥ទៅ ៣,៥គីឡូក្រាម/ក្បាល។





### ២-២-ការរៀបចំទីជម្រកទាតែវ៉ាន់

**ក)-<u>មានផ្ការបិទជិត</u>÷**

-មានសុវត្ថិភាពការពារពីសត្វកាចផ្សេងៗ

-កាត់បន្ថយការឆ្លងជំងឺពីខាងក្រៅ

-ងាយស្រួលក្នុងការគ្រប់គ្រង (ការផ្តល់ចំណី ការផ្តល់វ៉ាក់សាំង...)

-ងាយស្រួលក្នុងការប្រមូលផល

**ខ)-<u>ការសាងសង់ទ្រុង</u>÷**

-សង់ទ្រុងទាពីសម្ភារៈងាយៗស្រួលរក

-ទីតាំងស្រួលថែទាំ ទូលាយ ដីមិនស្អិត មិនដក់ទឹក និងមិនមានទឹកហូរឆ្លងកាត់

-មានប្រភពទឹកស្អាត មានម្លប់ជ្រក និងការពារពីខ្យល់បក់ខ្លាំង

-សង់ទ្រុងមានទទឹង ១០ម៉ែត្រ បណ្តោយ ៦០ម៉ែត្រ និងជំបូលមានកម្ពស់ពីដី ៣ម៉ែត្រ (ករណីចិញ្ចឹមទាតែវ៉ាន់ ២ ០០០ក្បាល) ។




**គ)-<u>ការរៀបចំអាងទឹកសិប្បនិម្មិតសម្រាប់ទាតែវ៉ាន់</u>**

ករណីកន្លែងចិញ្ចឹមទាតែវ៉ាន់មិនមានត្រពាំងឬស្រះទឹកនោះ កសិករត្រូវតែរៀបចំអាងទឹកដោយពុះធុងជ័រជាពីរចំណែក ឬចានដែកដាក់ទឹកឱ្យទាតែវ៉ាន់លេង និងសម្រាប់លាងសម្អាតខ្លួនជាប្រចាំ។ អ្នកចិញ្ចឹមទាគួរផ្លាស់ប្តូរទឹកអាងចេញពី១ ទៅ២ ដង/ថ្ងៃ អាស្រ័យទៅលើភាពកង្វក់របស់ទឹក។ ដើម្បីឱ្យទាមានសុខភាពល្អ កសិករត្រូវជីកមាត់អាងខាងលើក្នុងទំហំទទឹង និងបណ្តោយចាប់ពី១ម៉ែត្រឬលើសនេះក៏បាន និងផ្ទៃបាតស្រះធ្វើរាងជម្រាលមុំ ៤៥ដឺក្រេ ជម្រៅ០,២៥ ទៅ០,៣ម៉ែត្រ។ ។ជីកមាត់អាងខាងលើក្នុងទំហំទទឹង និងបណ្តោយចាប់ពី១ម៉ែត្រឬលើសនេះក៏បាន និងផ្ទៃបាតស្រះធ្វើរាងជម្រាលមុំ ៤៥ដឺក្រេ ជម្រៅ០,២៥ ទៅ០,៣ម៉ែត្រ។





## ២-៣-ការថែទាំកូនទាតែវ៉ាន់

- កូនទាតែវ៉ាន់ទើបញាស់ត្រូវការផ្តល់ទឹក ចំណី និងមានខ្យល់អាកាសចេញចូលល្អ
- រៀបចំដាក់កូនទាតែវ៉ាន់តូចៗឱ្យបានកក់ក្តៅ
- កូនទាតែវ៉ាន់ត្រូវចិញ្ចឹមកន្លែងមានសុវត្ថិភាព មិនមានសត្វកាចសាហាវ ឬសត្វផ្សេងៗមកបំផ្លាញ
- មិនត្រូវឱ្យកូនទានៅក្រោមទឹកភ្លៀងទេ ព្រោះកូនទាពុំអាចទប់ទល់នឹងអាកាសធាតុត្រជាក់បាន
- ត្រូវផ្តល់កម្តៅបន្ថែមដូចជា អំពូលភ្លើង ឬក្អមធ្យូង នៅពេលអាកាសធាតុចុះត្រជាក់ជាងធម្មតា
- ដាក់កូនទាតែវ៉ាន់ក្នុងទីធ្លាចិញ្ចឹម និងកន្លែងដេកស្របទៅតាមមាឌ អាយុ និងទំហំដងខ្លួន



**<u>បរិមាណអតិបរមានៃដង់ស៊ីតេដាក់ទាតៃវ៉ាន់ចិញ្ចឹមក្នុងទ្រុង</u>** (ដេកយប់) មានទីធ្លាបិទជិតគឺ÷

| អាយុទាតៃវ៉ាន់ (សប្តាហ៍) | សីតុណ្ហភាព (អង្សាសេ) | ដង់ស៊ីតេ (ក្បាល)/ម៉ែត្រការ៉េ |
|---|---|---|
| អាយុក្រោម ១សប្តាហ៍ | ៣២ - ៣៤ | ២០ - ៣០ |
| អាយុចន្លោះពី ១ ទៅ៤សប្តាហ៍ | ២៩ - ៣១ | ១០ - ២០ |
| អាយុចន្លោះពី ៤ ទៅ៦សប្តាហ៍ | ២៨ - ៣០ | ៥ - ១០ |
| អាយុចាប់ពី ៦សប្តាហ៍ឡើង | ២៦ - ២៨ | ៣ - ៥ |

### ២-៤-ទឹក និងចំណីទាតៃវ៉ាន់

តម្រូវការសារធាតុចិញ្ចឹមរបស់ទាតៃវ៉ាន់ក៏មិនខុសគ្នាពីបក្សីផ្សេងៗផងដែរ ដើម្បីលូតលាស់ ធំធាត់បន្តពូជ ទាត្រូវការសារធាតុចិញ្ចឹមសំខាន់ៗដូចជា÷ទឹក ប្រូតេអ៊ីន ថាមពល វីតាមីន និងសារធាតុរ៉ែ ដែលមាននៅក្នុងបន្លែបៃតង គ្រាប់ធញ្ញជាតិ សំបកក្តាមខ្យង ខ្ចៅ ដង្កូវ និងសត្វល្អិតផ្សេងៗ។ល។

**<u>កម្រិតប្រូតេអ៊ីនសម្រាប់ទាតៃវ៉ាន់អាស្រ័យទៅតាមអាយុរបស់ទា</u>** មានដូចខាងក្រោម÷

- ការផ្តល់ចំណីដល់កូនទាតៃវ៉ាន់តូចៗត្រូវធ្វើឡើងបន្ទាប់ពីកូនទាញាស់បាន ២៤ម៉ោង
- កូនទាអាយុពី១ថ្ងៃទៅ៣សប្តាហ៍ត្រូវការកម្រិតប្រូតេអ៊ីនខ្ពស់ពី២០ ទៅ២២%ដើម្បីចិញ្ចឹមសារពាង្គកាយ និងលូតលាស់យ៉ាងឆាប់រហ័ស
- អាយុទាចាប់ពី ៣សប្តាហ៍ទៅ ៨សប្តាហ៍ ត្រូវការកម្រិតប្រូតេអ៊ីនពី ១៦ទៅ១៨% ដើម្បីជួយដល់ការលូតលាស់ និងមិនធ្វើឱ្យទាធាត់ពេកនោះទេ
- អាយុទាចាប់ពី ៨សប្តាហ៍រហូតដល់ពេលលក់ ត្រូវការប្រូតេអ៊ីនក្នុងកម្រិត ១៤ ទៅ ១៦% សម្រាប់ការលូតលាស់ធំធាត់ដើម្បីលក់ផ្គត់ផ្គង់តម្រូវការជាទាសាច់។

**<u>តម្រូវការទឹក</u>** ÷

ទឹកមានសារៈសំខាន់ចូលរួមជួយដំណើរការលូតលាស់របស់សត្វទា។ ទឹកធ្វើឱ្យចំណីទន់ និងជួយដល់ការរំលាយអាហារ ការស្រូប និងការដឹកជញ្ជូនសារធាតុចិញ្ចឹមទៅគ្រប់សរីរាង្គ។



**<u>ចំណាំ</u>**÷ ទាតៃវ៉ាន់ផឹកទឹកមិនគ្រប់គ្រាន់អាចបណ្តាលឱ្យការរំលាយអាហារមិនបានល្អ មិនមានភាពស្វាហាប់ រហ័សរហួន។

## ៣- វិធី ការការពារ និងការថែរក្សាសុខភាពទាតែវ៉ាន់

សត្វទាតែវ៉ាន់តែងតែជួបប្រទះជាញឹកញាប់នូវជំងឺមួយចំនួនដូចខាងក្រោម ÷

### ៣-១-ជំងឺផ្តាសាយបក្សី ÷

អាចកើតមានឡើងលើទាតែវ៉ាន់គ្រប់វ័យ

<u>**រោគសញ្ញា**</u>÷

-ទាមានអត្រាងាប់ខ្ពស់ ងាប់លឿន (រោគសញ្ញា ឬស្លាកស្នាមមិនអាចកើតមាន)

- មានសភាពងងុយដេក ក្បាលសំយ៉ុងចុះប៉ះដី

-ភ្នែកឡើងស ត្របកភ្នែកហើម

-រាគលាមកពណ៌ស

*ចំណាំ÷ជំងឺផ្តាសាយបក្សីមិនមានការព្យាបាលនោះទេ*

<u>**វិធីសាស្រ្តការពារ**</u> ÷

-កសិករត្រូវអនុវត្តវិធានជីវសុវត្ថិភាពចំពោះសត្វចិញ្ចឹម

-ក្រុងបក្សីដែលទិញពីផ្សារ ឬនាំមកថ្មីឱ្យនៅដាច់ដោយឡែកមុនពេលដាក់ចូលក្នុងហ្វូង។

-ទាអាចផ្ទុកជំងឺយ៉ាងស្ងៀមស្ងាត់ និងឆ្លងទៅបក្សីក្នុងភូមិ បណ្តាលឱ្យផ្ទុះជំងឺ

-ចិញ្ចឹមបក្សីដាក់ទ្រុង ប្រើសំណាញ់ព័ន្ធជុំវិញ ដើម្បីចៀសវាងការប៉ះពាល់ជាមួយបក្សីព្រៃ

-វីរុសឆ្លងតាមរយៈស្បែកជើង សម្លៀកបំពាក់ និងដៃ ដូច្នេះកសិករត្រូវលាងដៃ និងសម្អាតស្បែកជើងជាមួយសាប៊ូមុនពេលចូលទៅកសិដ្ឋានចិញ្ចឹម ដើម្បីកាត់បន្ថយគ្រោះថ្នាក់ក្នុងការចម្លងមេរោគ។

### ៣-២-ជំងឺប៉េស្តទាតែវ៉ាន់ ÷

ជំងឺនេះបណ្តាលមកពីវីរុស មេរោគនៃជំងឺប៉េស្តចូលចិត្តរស់នៅក្នុងពោះវៀន និងកន្ទ្រាមពង ឬឯខាងក្រៅខ្លួនសត្វវាចូលចិត្តរស់នៅក្នុងទឹក។

<u>**រោគសញ្ញា**</u>÷

-រយៈពេលបង្កជំងឺពី ២ទៅ១០ថ្ងៃ លើទាគ្រប់វ័យ

-អត្រាស្លាប់មានដល់ ១០០%

-ទាដែលមានវ័យចាស់ទទួលជំងឺខ្លាំងជាងទាក្មេង

-ទាសំកុកដេកផ្ទាល់នឹងដីមិនសូវធ្វើចលនា ធ្លាក់ស្លាបមានសំបោរចេញពីច្រមុះ រង្វង់ភ្នែកក្រហមជាំ

-រាគ លាមកមានសណ្ឋានជាទឹក ឬជារាគឈាម រោមមានប្រឡាក់ដី ឬឈាម

-ទាស្រេកទឹកខ្លាំង ទាច្រើនស្លាប់ដោយរមូលកទៅក្រោយ ឬទៅចំហៀងខ្លួន។

**ការឆ្លងរាលដាល÷**

-វីរុសនៃជំងឺប៉េស្ដទាចេញពីដងខ្លួនសត្វមកក្រៅតាមលាមក ឬសារធាតុរាវផ្សេងៗចេញពីខ្លួនសត្វឈឺ ឬស្លាប់ ចូលក្នុងទឹក ចំណី ដែលបណ្ដាលឱ្យឆ្លងទៅទាផ្សេងៗ និងសត្វកកេរដទៃទៀតនាំឱ្យមេរោគបង្កជំងឺពីកន្លែងមួយទៅកន្លែងមួយ

**វិធីសាស្ត្រការពារនិងព្យាបាល÷**

-ពុំមានថ្នាំព្យាបាលទេ ព្រោះជំងឺនេះបណ្ដាលមកពីវីរុស

-ត្រូវចាក់វ៉ាក់សាំងការពារជំងឺប៉េស្ដទាតែវ៉ាន់

-ទិញកូនទាពីកន្លែងដែលគ្មានជំងឺ

-អនាម័យ (លាងសម្អាតស្នូកទឹក ស្នូកចំណី) ហាមសត្វបក្សីផ្សេងៗចូលក្នុងទ្រុងទា

## ៤-តម្លៃ និងទីផ្សារ

**៤-១-តម្លៃ÷** ឈ្មួញប្រមូលទិញទាក្នុងតម្លៃបោះដុំថេរពេញមួយឆ្នាំគឺ ៧,០០០ ទៅ ៩,០០០រៀល/គ.ក្រ។

**៤-២-ទីផ្សារ÷** កសិករអាចលក់ទាតែវ៉ាន់សាច់រស់ចេញទៅឈ្មួញកណ្ដាលដែលមកយកដល់កសិដ្ឋានទៅលក់បន្តនៅភ្នំពេញ និងចែកចេញតាមទីប្រជុំជន និងទីផ្សារ។

**៤-៣-គម្រោងនៃការចំណាយលើការចិញ្ចឹមទាតែវ៉ាន់ចំនួន ២,០០០ក្បាល/វគ្គ**

គម្រោងចិញ្ចឹមទាតែវ៉ាន់នេះត្រូវបានក្រុមការងារបានចុះសិក្សានៅកសិដ្ឋានចិញ្ចឹមទាតែវ៉ាន់ នៅឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្ដាល។

-ទំហំផ្ទៃកសិដ្ឋានសរុប÷ ០,៥ហិកតា

-ចំនួនវគ្គ/ឆ្នាំ÷ ៤វគ្គ/ឆ្នាំ (១វគ្គប្រើពេល៥០ទៅ៦០ថ្ងៃនិងទុកទ្រុងឱ្យទំនេរកន្លះខែទៅ១ខែ ដើម្បីសម្អាត បាញ់ថ្នាំសម្លាប់មេរោគ)

-ទំហំទ្រុង÷ ទទឹង១០ម៉ែត្រ និងបណ្ដោយ៦០ម៉ែត្រ

ទុនចំណាយពេលចាប់ផ្ដើម÷ ៤៣,០៦៥,០០០រៀល ក្នុងនោះរួមមាន÷

| ចំណាយវិនិយោគលើការរៀបចំទ្រុង របង និងឧបករណ៍សម្ភារៈផ្សេងៗ (ជារៀល) | ចំណាយលើការចិញ្ចឹម-ថែទាំ ចំណី និងថ្នាំ (ជារៀល) | ចំណាយសរុប (ជារៀល) |
|---|---|---|
| **12,777,500** | **30,287,500** | **43,065,000** |

**៤-៤-ការប្រមូលផលទាតែវ៉ាន់÷**

ដោយផ្អែកលើនិន្នាការតម្លៃ និងអត្រាស្លាប់កូនទាតែវ៉ាន់អាយុក្រោម១សប្តាហ៍ ៥ ទៅ១៥%នៃទាសរុប

-ទាតែវ៉ាន់សាច់អាចមានទម្ងន់ពី២,៥ទៅ៣,៥គ.ក្រ/ក្បាល (ជាមធ្យមទម្ងន់ទាតែវ៉ាន់សាច់ ៣គ.ក្រ/ក្បាល សម្រាប់ការចិញ្ចឹមរយៈពេល ៦០ថ្ងៃ)

-អត្រាបាត់បង់ជាមធ្យមអាចមានចន្លោះពី ៥%ទៅដល់១៥% គឺអាស្រ័យលើការថែទាំ ចំណី ទឹក និងពូជ

-*តាមរយៈការសិក្សា* កសិដ្ឋានចិញ្ចឹមទាតែវ៉ាន់មានអត្រាបាត់បង់ ១០% នៃចំនួនទាសរុប

-***សម្គាល់÷*** ការចិញ្ចឹមទាតែវ៉ាន់ក្នុង១វគ្គមានរយៈពេលជាង ២ខែ ដោយទុកចន្លោះរយៈពេល១ខែ ដើម្បីសម្អាតទ្រុង និងប្រើថ្នាំសម្លាប់មេរោគ មុនដាក់កូនទាតែវ៉ាន់ថ្មីចូល ដូច្នេះអាចចិញ្ចឹមបានចំនួន៤វគ្គ/ឆ្នាំ។

**៥-ការវិភាគសេដ្ឋកិច្ច** ÷ លើការចិញ្ចឹមទាតែវ៉ាន់សាច់ចំនួន ២,០០០ក្បាល/វគ្គ÷

ទម្ងន់ជាមធ្យម ៣គ.ក្រ/ក្បាល តម្លៃជាមធ្យម ៨,០០០រៀល/គ.ក្រ

| បរិយាយ | ឯកត្តា | ចំនួន ឯកត្តា | តម្លៃ ១ឯកត្តា | ទឹកប្រាក់ សរុប (រៀល) | ចំនួនសារ វិលស់ | ទឹកប្រាក់ សរុប (រៀល) |
|---|---|---|---|---|---|---|
| **១-ចំណូលសរុប/(២ខែ)** | | | | | | **43,200,000** |
| ចំណូលពីការលក់ទាតែវ៉ាន់ | ក្បាល | 1,800 | 24,000 | 43,200,000 | | 43,200,000 |
| **២-ចំណាយសរុប = ចំណាយប្រែប្រួល + ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **30,758,792** |
| **២.ក.ចំណាយប្រែប្រួល** | | | | | | **30,287,500** |
| កូនទាតែវ៉ាន់ | ក្បាល | 2000 | 3,500 | 7,000,000 | | 7,000,000 |
| ចំណីកូនទា | គ.ក្រ | 1,500 | 1,600 | 2,400,000 | | 2,400,000 |
| ចំណីទាសាច់ | គ.ក្រ | 12,000 | 1,500 | 18,000,000 | | 18,000,000 |
| ថ្លៃអគ្គិសនី | គី.វ៉ាត់ | 150 | 730 | 109,500 | | 109,500 |
| ថ្នាំ និងវិតាមីន | គ.ក្រ | 20 | 25,000 | 500,000 | | 500,000 |
| វ៉ាក់សាំងប៉េស្តទា | ដប | 2 | 20,000 | 40,000 | | 40,000 |
| វ៉ាក់សាំងអាសន្នរោគ | ដប | 2 | 80,000 | 160,000 | | 160,000 |
| វ៉ាក់សាំងផ្តាសាយ | ដប | 4 | 100,000 | 400,000 | | 400,000 |

| | | | | | | |
|---|---|---|---|---|---|---|
| កម្លាំងពលកម្ម | ខែ | 2 | 800,000 | 1,600,000 | | 1,600,000 |
| ថ្នាំទម្លាក់សត្វល្អិត | កញ្ចប់ | 1 | 30,000 | 30,000 | | 30,000 |
| ថ្នាំសម្លាប់មេរោគ | ដប | 2 | 24,000 | 48,000 | | 48,000 |
| **២.ខ.ចំណាយមិនប្រែប្រួល/ថេរ (ក្នុង២ខែ)** | | | | **12,777,500** | | **471,292** |
| រោងទាតែវ៉ាន់ (ទទឹង១០ ម៉ែត្រ បណ្តោយ៦០ម៉ែត្រ) | រោង | 1 | 12,000,000 | 12,000,000 | 30 | 400,000 |
| សំណាញ់ព័ន្ធជុំវិញទ្រុង | គ.ក្រ | 15 | 25,000 | 375,000 | 30 | 12,500 |
| កម្រាល(ចំបើង និងអង្កាម) | ដុំ | 1 | 5,000 | 5,000 | 1 | 5,000 |
| ស្នូកទឹក | ចំនួន | 4 | 80,000 | 320,000 | 30 | 10,667 |
| ស្នូកចំណី | ចំនួន | 15 | 2,500 | 37,500 | 12 | 3,125 |
| អំពូលកម្តៅ | ចំនួន | 10 | 4,000 | 40,000 | 1 | 40,000 |
| **៣-ចំណេញសរុប** | | | | | | **12,441,208** |
| **ថ្លៃដើមចំណាយសរុបលើទាតែវ៉ាន់ ១ក្បាល (៣គ.ក្រ)** | | | | | | **17,088** |
| **ចំណេញលើទាតែវ៉ាន់ ១ក្បាល** | | | | | | **6,912** |

**ប្រភព**÷ចុះសាកសួរកសិករចិញ្ចឹមទាតែវ៉ាន់នៅឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល

### ៥-១-ការវិភាគលើតម្លៃលក់ទាតែវ៉ាន់សាច់អាយុ២ខែ

| ចំនួនទា | ទម្ងន់/ក្បាល | ទម្ងន់សរុប | តម្លៃ/គ.ក្រ | ចំណូលសរុប | ចំណាយសរុប | ចំណេញសរុប |
|---|---|---|---|---|---|---|
| 1,800 | 3 | 5,400 | 7,000 | 37,800,000 | 30,758,792 | 7,041,208 |
| 1,800 | 3 | 5,400 | 7,500 | 40,500,000 | 30,758,792 | 9,741,208 |
| **1,800** | **3** | **5,400** | **8,000** | **43,200,000** | **30,758,792** | **12,441,208** |
| 1,800 | 3 | 5,400 | 8,500 | 45,900,000 | 30,758,792 | 15,141,208 |
| 1,800 | 3 | 5,400 | 9,000 | 48,600,000 | 30,758,792 | 17,841,208 |

## ៥-២-ការវិភាគនៅលើអត្រាបាត់បង់( ៥%,១០%,១៥%)

| អត្រាបាត់បង់ (%) | ចំនួនក្បាល | ទម្ងន់/ក្បាល | ទម្ងន់សរុប | តម្លៃ ៛/គ.ក្រ | ចំណូលសរុប (៛) | ចំណាយសរុប (៛) | ចំណេញសរុប (៛) |
|---|---|---|---|---|---|---|---|
| 5 | 1,900 | 3 | 5,700 | 8,000 | 45,600,000 | 30,758,792 | 14,841,208 |
| 10 | 1,800 | 3 | 5,400 | 8,000 | 43,200,000 | 30,758,792 | 12,441,208 |
| 15 | 1,700 | 3 | 5,100 | 8,000 | 40,800,000 | 30,758,792 | 10,041,208 |

## ៦-ហានិភ័យ វិធានការ និងអនុសាសន៍÷

តាមរយៈនៃការចុះស្វែងយល់ដល់កសិដ្ឋាន កសិករចិញ្ចឹមទាអាចនឹងជួបប្រទះនូវហានិភ័យមួយចំនួនជាយថាហេតុលើដំណើរការចិញ្ចឹមទាតែវ៉ាន់ដែលនាំឱ្យបង្កផលវិបាក និងប៉ះពាល់ដល់សមត្ថភាពផលិតកម្ម ដូចនេះកសិករគួររៀបចំផែនការជាក់លាក់ដើម្បីកាត់បន្ថយ ឬគ្រប់គ្រងលើហានីភ័យប្រកបដោយប្រសិទ្ធភាពខ្ពស់។ ហានិភ័យទាំងនោះរួមមាន÷

| ល.រ | ប្រភេទហានិភ័យ | ការពិពណ៌នាពីហានិភ័យ | វិធានការ និងអនុសាសន៍ |
|---|---|---|---|
| ១ | ហានិភ័យផលិតកម្ម | កូនទាតែវ៉ាន់ដែលមានជំងឺតពូជពីមេបា និងកូនទាតែវ៉ាន់ដែលមានសុខភាពខ្សោយ ដឹកជញ្ជូនយូរពេក | -សិក្សាប្រវត្តិពីកសិដ្ឋានលក់ពូជឱ្យបានច្បាស់លាស់អំពីមេបាពូជ<br>-ត្រូវរើសកូនទាតែវ៉ាន់ដែលមានសុខភាពល្អមានទំហំប៉ុនៗគ្នា មានរោមភ្លឺរលោង មិនស្វិតជើង<br>-សន្ទាក់ជើងល្អ ដំណើររហ័សរហួន សំឡេងឮច្បាស់<br>-មានកែវភ្នែកភ្លឺថ្លា<br>-តាមដានទម្ងន់មេបា និងប្រវត្តិដើមនៃការបង្កាត់ពូជ |
| | | កង្វះខាតទីធ្លា ពុំមានស្រះទឹកសម្រាប់ទាហែលលេង និងខ្វះទឹកស្អាតសម្រាប់ផឹក | -មានទំហំសមាមាត្រនឹងចំនួនទាតែវ៉ាន់<br>-មានរៀបចំស្រះទឹកសម្រាប់ទាតែវ៉ាន់ហែលលេង<br>-មានទឹកស្អាតសម្រាប់ផឹកគ្រប់គ្រាន់ជាប្រចាំ<br>-រៀបចំកម្រាលទ្រុងស្ងួតល្អ ពិសេសពេលកូនទាតែវ៉ាន់នៅតូច<br>-ផ្តល់កម្តៅឱ្យបានគ្រប់គ្រាន់ |
| ២ | ហានិភ័យទីផ្សារ | តម្លៃទីផ្សារទាតែវ៉ាន់ប្រែប្រួលមិនច្បាស់លាស់ | -ស្វែងរកទីផ្សារ ឬឈ្មួញប្រមូលទិញឱ្យបានច្រើន<br>-ស្វែងរកហាង ភោជនីយដ្ឋានដែលមានតម្រូវការជាប្រចាំ និងលទ្ធភាពផ្គត់ផ្គង់ច្បាស់លាស់<br>-រកទីផ្សារលក់រាយក្នុងតំបន់ទៅអ្នកបរិភោគផ្ទាល់ |

| | | | |
|---|---|---|---|
| ៣ | **ហានិភ័យ ហិរញ្ញវត្ថុ** | ខ្វះថវិកានៅក្នុងដំណើរការចិញ្ចឹម ពេលខ្លះត្រូវបង្ខំចិត្តលក់ទាំងទាពុំទាន់គ្រប់ទម្ងន់ស្តង់ដា | -មានផែនការអាជីវកម្មច្បាស់លាស់<br>-មានទុនបម្រុងក្រៅពីទុនវិនិយោគ<br>-ត្រូវរកទុនឥណទានដែលមានអត្រាការប្រាក់ទាបសមរម្យ<br>-កំណត់បរិមាណទាដែលត្រូវចិញ្ចឹមទៅតាមទំហំទុន<br>-ដាក់ទាតៃវ៉ាន់ចិញ្ចឹមក្នុងទ្រុងនូវបរិមាណសមស្រប ដោយដាក់ចិញ្ចឹមវិលជុំ |
| ៤ | **ហានិភ័យ បរិស្ថាន** | មានក្លិនស្អុយសាយភាយទៅអ្នករស់នៅជិតខាង | -ត្រូវចិញ្ចឹមនៅក្នុងចម្ការ ឬឆ្ងាយពីផ្ទះប្រជាជនរស់នៅ<br>-ត្រូវធ្វើអនាម័យជាប្រចាំ និងរៀបចំប្រព័ន្ធជីវសុវត្ថិភាព |

## ៧-សេចក្តីសន្និដ្ឋាន

ទាតៃវ៉ាន់ជាបក្សីធំធាត់លឿន ធន់ខ្លាំងទៅនឹងអាកាសធាតុត្រជាក់ ងាយស្រួលចិញ្ចឹម និងផ្តល់ចំណីព្រមទាំងមានទីផ្សារល្អទាំងបោះដុំនិងលក់រាយ។ តាមការចុះសិក្សាជាក់ស្តែងការចិញ្ចឹមទាតៃវ៉ាន់របស់កសិករនៅខេត្តកណ្តាល លើការចិញ្ចឹមទាតៃវ៉ាន់សាច់ ២,០០០ក្បាល ដោយប្រើពេល២ខែ/វគ្គ ទទួលបានទម្ងន់ជាមធ្យម ៣គ.ក្រ/ក្បាល ស្មើនឹង ២៤,០០០រៀល/ក្បាល ដោយចំណាយថ្លៃដើមផលិត១៧,០៨៨រៀល/ក្បាល ទទួលបានប្រាក់ចំណេញប្រមាណ ៦,៩១២រៀល/ក្បាល។ ក្នុង ១វគ្គកសិករអាចទទួលបានប្រាក់ចំណេញជាង ១២លានរៀល ប៉ុន្តែប្រាក់ចំណេញអាចប្រែប្រួលអាស្រ័យលើអត្រាបាត់បង់ និងតម្លៃលក់លើទីផ្សារ។ ដើម្បីទទួលបានប្រាក់ចំណេញច្រើន កសិករគួរគិតគូរលើកត្តាចាំបាច់មួយចំនួនដូចជា ការជ្រើសរើសកូនទាពូជ ការថែទាំដោយធ្វើអនាម័យស្នូកទឹក ចំណី និងអាងទឹកសម្រាប់ទាចុះសម្អាតខ្លួន គុណភាពចំណីសមស្របនឹងតម្លៃ ធ្វើកម្មវិធីវ៉ាក់សាំងឱ្យបានទៀងទាត់ និងមានទីផ្សារបោះដុំច្បាស់លាស់។

**ប្រភពនៃការសិក្សាស្រាវជ្រាវ**

១/ កសិករចិញ្ចឹមទាតៃវ៉ាន់នៅឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្តាល

២/ Pekin Ducks: Guide to Raising the Most Popular Meat Duck

៣/ Pekin Duck Guide: Everything You Need to Know — Roobeez

៤/ Pekin Duck vs Muscovy Duck - What is the Difference? - LearnPoultry